# ព្រះរាជក្រម

នស/រកម/១០០៧/០២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសារឆ្នាំ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងពិធីសារឆ្នាំ ១៩៧២ ដែលបានធ្វើវិសោធនកម្ម អនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសារឆ្នាំ ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៧១០.៥៣៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**ហត្ថលេខា**
**ស ខេង**

លេខៈ ៤៩៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃួន ជិនកេន**

# អនុសញ្ញាទោល

## ស្តីពី

## គ្រឿងញៀន ឆ្នាំ ១៩៦១

ដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២ ដែលបានកែប្រែអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១

រួមបញ្ចូល តារាង ច្បាប់ និងសេចក្តីសំរេចចុងក្រោយ ដូចបានព្រមព្រៀង ដោយសន្និសីទរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៦១ សំរាប់ការអនុម័តអនុសញ្ញាទោល ស្តីពី គ្រឿងញៀន និងដោយសន្និសីទរបស់អង្គការសហប្រជាជាតិ ឆ្នាំ ១៩៧២ ដើម្បីពិចារណាលើការធ្វើវិសោធនកម្មចំពោះអនុសញ្ញាទោល ស្តីពី គ្រឿងញៀន ឆ្នាំ ១៩៦១ ។

អង្គការសហប្រជាជាតិ

# ច្បាប់ចុងក្រោយនៃសន្និសីទរបស់អង្គការសហប្រជាជាតិ សំរាប់ការអនុម័តអនុសញ្ញាគោល ស្តីពី គ្រឿងញៀន

១- តាមរយៈសេចក្តីសំរេចលេខ ៦៨៩ J (XXVI) ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥៨ ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិបានសំរេចកោះប្រជុំ ដោយអនុលោមទៅតាមមាត្រា ៦២ កថាខ័ណ្ឌទី៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយដោយយោងទៅតាមបទបញ្ញត្តិនៃសេចក្តីសំរេចរបស់មហាសន្និបាតលេខ៣៦៦(IV) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៤៩ សន្និបាតពេញអង្គសំរាប់ការអនុម័តនៃអនុសញ្ញាគោលស្តីពីគ្រឿងញៀន ដើម្បីជំនួសដោយលិខិតទុបករណ៍គោលមួយ ការមានសន្ធិសញ្ញាពហុភាគីក្នុងការអនុវត្តន៍ ដើម្បីកាត់បន្ថយនូវចំនួនសន្ធិសញ្ញាអន្តរជាតិដែលទាក់ទងទៅនឹងការត្រួតពិនិត្យគ្រឿងញៀន ហើយដើម្បីបង្កើតបទបញ្ញត្តិសំរាប់ត្រួតពិនិត្យផលិតផលនៃវត្ថុធាតុដើមគ្រឿងញៀន។

២- សន្និសីទអង្គការសហប្រជាជាតិសំរាប់ការអនុម័តអនុសញ្ញាគោល ស្តីពីគ្រឿងញៀន បានជួបប្រជុំគ្នានៅទីបញ្ជាការរបស់អង្គការសហប្រជាជាតិ ចាប់ពីថ្ងៃទី ២៤ ខែមករា រហូតដល់ ២៥ ខែមីនា ឆ្នាំ១៩៦១ ។

៣- បណ្តារដ្ឋទាំង ៧៣ ខាងក្រោមនេះបានបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងសន្និសីទមាន :

ប្រទេស

Afghanistan
Albania
Argentina
Australia
Bolivia
Brazil
Bulgaria
Burma
Byelorussian Soviet So-
-cialist Republic
Cambodia
Canada
Chad
Chile
China
Congo (Leopoldville)
Costa Rica
Greece
Guatemala
Haiti
Holy See
Hungary
India
Indonesia
Iran
Iraq
Israel
Italy
Japan
Jordan
Korea, Republic of
Lebanon
Liberia
Madagascar
Paraguay
Peru
Philippines
Poland
Portugal
Romania
Senegal
Spain
Sweden
Switzerland
Thailand
Tunisia
Turkey
Ukrainian Soviet Socialist
Republic
Union of Soviet Socialist
Republics

Czechoslovakia
Dahomey
Denmark
Dominican Republic
El Salvador
Finland
France
Germany, Federal Re-
-public of
Ghana
Mexico
Monaco
Morocco
Netherlands
New Zealand
Nicaragua
Nigeria
Norway
Pakistan
Panama
United Arab Republic
United Kingdom of
Great Britain and
Northern Ireland
United States of America
Uruguay
Venezuela
Yugoslavia

៤- ប្រទេសមួយខាងក្រោមនេះ បានបញ្ជូនអ្នកសង្កេតការម្នាក់អោយចូលរួមក្នុងសន្និសីទ គឺប្រទេស Ceylon

៥- ភ្នាក់ងារជំនាញពិសេសដែលបានចូលរួមក្នុងសន្និសីទនោះ រួមមាន : អង្គការកសិកម្មម្ហូបអាហាររបស់អង្គការសហប្រជាជាតិ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ អង្គការពលកម្មអន្តរជាតិ និងអង្គការសុខភាពពិភពលោក ។

៦- អង្គការតំណាងអន្តរជាតិ ដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន :
គណៈកម្មការកណ្តាលអចិន្ត្រៃយ៍ប្រឆាំងនឹងអាភៀន
អង្គការត្រួតពិនិត្យគ្រឿងញៀន

៧- អង្គការក្រៅរដ្ឋាភិបាលដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន:
អង្គការសន្និសីទសប្បុរសធម៌កាតូលិកអន្តរជាតិ អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ អង្គការសហព័ន្ធមេធាវីស្ត្រីអន្តរជាតិ ។

៨- ឧត្តមសេនីយ៍ Safwat, នាយកការិយាល័យប្រឆាំងគ្រឿងញៀនអចិន្ត្រៃយ៍របស់សម្ព័ន្ធមិត្តអារ៉ាប់ ក៏បានចូលដោយផ្ទាល់តាមរយៈការអញ្ជើញរបស់សន្និសីទនោះផងដែរ ។

៩- យោងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម ដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ និងជាមួយវិធាននីតិវិធីដែលបានអនុម័តដោយសន្និសីទនោះ អ្នកសង្កេតការណ៍ និងអ្នកតំណាងរបស់អង្គការដែលបានរៀបរាប់ខាងលើ និងអង្គការតំណាង ដែលបានចូលរួមនៅក្នុងការងារសន្និសីទ គ្មានសិទ្ធិបោះឆ្នោតទេ ។